**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីការស្រាវជ្រាវរកឃើញកាហ្វេឈ្មោះ MA KHAW (សញ្ញាសេះស) មានផ្ទុកនូវសារធាតុដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងសុខាភិបាលបានទទួលព្រឹត្តិប័ត្រវិភាគគុណភាពពីមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដែលបញ្ជាក់ថា កាហ្វេឈ្មោះ MA KHAW (សញ្ញាសេះស) Box = 15g x 10 Sachets + 1 Capsule មានលួចដាក់សារធាតុឱសថសម័យដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។ យោងតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ មាត្រា២ថ្មី កាហ្វេឈ្មោះ MA KHAW (សញ្ញាសេះស) Box = 15g x 10 Sachets + 1 Capsule ដែលកំពុងផ្សព្វផ្សាយលក់នៅតាមបណ្តាញសង្គមហ្វេសប៊ុកដែលមានគណនីឈ្មោះ ១-ស្តេចកាហ្វេ ២-បិតាកាហ្វេ 0962221811 ៣-កាហ្វេប៉ូវកម្លាំងបុរស និងតាមប្រព័ន្ធអនឡាញមួយចំនួនត្រូវចាត់ទុកជាឱសថ ដែលរាល់ការប្រើប្រាស់ត្រូវមានវេជ្ជបញ្ជា និងមានការប្រុងប្រយ័ត្នបំផុត។ ដើម្បីធានានូវសុវត្ថិភាពដល់សាធារណជនទូទៅក្រសួងសុខាភិបាលតម្រូវឱ្យនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត សូមណែនាំដល់ឯកឧត្តម លោកជំទាវប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត អាជ្ញាធរមានសមត្ថកិច្ចឱ្យធ្វើការស្រាវជ្រាវ និងប្រមូលត្រឡប់មកវិញនូវផលិតផលខាងលើនេះ ដែលបានលក់នៅតាមបណ្តាញសង្គមហ្វេសប៊ុក និងតាមមធ្យោបាយផ្សេងទៀតមកកម្ទេចចោល។

*បន្ទាប់ពីផ្សព្វផ្សាយប្រកាសព័ត៌មានផលិតផលខាងលើនេះរួចហើយ បើសិនមានម្ចាស់គណនីបណ្តាញសង្គមហ្វេសប៊ុក និងជនពាក់ព័ន្ធណាមួយនៅតែបន្តនាំចូល ចែកចាយ ផ្សព្វផ្សាយលក់ ផលិតផលខាងលើនេះជាបន្តទៀតនឹងត្រូវទទួលទោសតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។*

ក្រសួងសុខាភិបាល សូមជូនព័ត៌មានដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវបញ្ឈប់ការទិញ និងប្រើប្រាស់កាហ្វេឈ្មោះ MA KHAW (សញ្ញាសេះស) Box = 15g x 10 Sachets + 1 Capsule ក្លែងក្លាយនេះជាបន្ទាន់ ព្រោះផលិតផលនេះអាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរ ឬឈានដល់ការបាត់បង់អាយុជីវិតទៀតផង។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋបានជួបប្រទះឃើញជនណាកំពុងនាំចូល ចែកចាយ ឬលក់កាហ្វេឈ្មោះ MA KHAW (សញ្ញាសេះស) Box = 15g x 10 Sachets + 1 Capsule ខាងលើនេះ សូមបងប្អូនប្រញាប់ផ្តល់ព័ត៌មាន ឬត្រូវការព័ត៌មានបន្ថែមពីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ៖ ០១២ ៣៥៥ ១៦១, ០១១ ៥៧៤ ៧៨៧, ០១២ ៩៨៣ ៣៣៤, ០១៧ ៦០៦ ៦៧០, ០១៧ ៨៦៦ ៧៦០។

សូមភ្ជាប់ជាមួយនូវរូបភាពកាហ្វេឈ្មោះ MA KHAW (សញ្ញាសេះស)។

ថ្ងៃចន្ទ ៦ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២១

## រូបភាពកាហ្វេឈ្មោះMA KHAW ( សញ្ញាសេះស )

## Box = 15gx10 Sachets + 1 Capsule ក្លែងក្លាយ




**ហាមលក់ ហាមទិញ ហាមប្រើប្រាស់ អាចបណ្តាឱ្យគ្រោះថ្នាក់ដល់អាយុជីវិត**




ស្តេចកាហ្វេ
1 d ·

☎ខលមក 0962221811 - 077277022 - 0886065666
១ប្រអប់ 35$ ចុះសល់ 25$
ពិសារភ្លាមខ្លាំងភ្លាម ត្រឹម១កញ្ចប់
មានសេវាកម្មដឹកជញ្ជូនរហ័សទាន់ចិត្ត គ្រប់ខេត្ត/ក្រុង




ស្តេចកាហ្វេ
Vitamins/ supplements
Like

# រូបភាពកាហ្វេឈ្មោះMA KHAW ( សញ្ញាសេះស )

## Box = 15gx10 Sachets + 1 Capsule ក្លែងក្លាយ







**ហាមលក់ ហាមទិញ ហាមប្រើប្រាស់ អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់អាយុជីវិត**




